IFAD Investing in rural people

សេចក្តីប្រកាសព័ត៌មាន

# IFAD និងកម្ពុជាចុះហត្ថលេខាលើកិច្ចព្រមព្រៀងបើកការិយាល័យអង្គការ IFAD ប្រចាំប្រទេសជាប្រវត្តិសាស្រ្ត

ទីក្រុងរ៉ូម ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ - កាលពីដើមខែសីហានេះ មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍វិស័យកសិកម្ម (IFAD) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបើកការិយាល័យអង្គការ IFAD ប្រចាំប្រទេសជាប្រវត្តិសាស្រ្ត ជាមួយព្រះរាជាណាចក្រកម្ពុជា ដែលជាការឈានដល់ចំណុចខ្ពស់បំផុតនៃកិច្ចគាំទ្រ និងវិនិយោគរយៈពេលជិត២០ឆ្នាំនៅតាមតំបន់ជនបទក្នុងប្រទេសនេះ។ គិតចាប់ពីឆ្នាំ១៩៩៦មក គ្រួសារជនបទក្រីក្រនិងគ្រួសារជួបការលំបាក ចំនួន១,២លានគ្រួសារបានទទួលអត្ថប្រយោជន៍ពីកិច្ចសហប្រតិបត្តិការរបស់អង្គការ IFAD ជាមួយនឹងព្រះរាជាណាចក្រកម្ពុជា។

កិច្ចព្រមព្រៀងទទួលការិយាល័យអង្គការ IFAD នឹងធ្វើឲ្យភាពជាដៃគូរវាងព្រះរាជាណាចក្រកម្ពុជា និង IFAD កាន់តែរឹងមាំ ហើយក៏នឹងពន្លឿនកិច្ចសហការក្នុងការអនុវត្តគម្រោងដែលគាំទ្រដោយមូលនិធិ IFAD ។ អង្គការIFAD នឹងបន្តដើរតួនាទីនាំមុខ នៅក្នុងការពង្រឹងជីវភាពប្រជាជនជនបទឲ្យកាន់តែមានលក្ខណៈប្រសើរឡើង និងផ្តល់សិទ្ធិអំណាចដល់កសិករខ្នាតតូច តាមរយៈការបង្កើនប្រាក់ចំណូល និងកម្រិតជីវភាពរបស់ពួកគាត់។

កិច្ចព្រមព្រៀងបើកការិយាល័យអង្គការ IFAD ប្រចាំប្រទេសត្រូវបានចុះហត្ថលេខានៅទីក្រុងរ៉ូម នាថ្ងៃទី១១ ខែសីហា ដោយលោក Kanayo F. Nwanze ប្រធានអង្គការ IFAD និងឯកឧត្តមអូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចព្រមព្រៀងនេះគឺជាជំហានដ៏មានសារៈសំខាន់ ចំពោះការបង្កើតការិយាល័យប្រចាំប្រទេស IFAD នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

លោក Benoit Thierry ដែលជាប្រធានកម្មវិធីប្រចាំប្រទេសរបស់ IFAD សម្រាប់ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសហ្វីលីពីន និងប្រទេសថៃបានមានប្រសាសន៍ថា "ការបង្កើតការិយាល័យប្រចាំប្រទេស IFAD នៅក្នុងព្រះរាជាណាចក្រកម្ពុជានឹងជួយដល់យើង នៅក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ ព្រមទាំងពង្រឹងកិច្ចសហការរបស់ IFAD ជាមួយនឹងដៃគូអភិវឌ្ឍផ្សេងៗទៀត ដែលចូលរួមនៅក្នុងការអភិវឌ្ឍកសិកម្ម និងជនបទ"។ "យើងនឹងបន្តគាំទ្រប្រទេសកម្ពុជា នៅក្នុងការជួយកសិករដែលមានដីតិចលើការបង្កបង្កើនផលិតកម្មកសិកម្ម និងទាញយកអត្ថប្រយោជន៍ពីឱកាសទីផ្សារ ក្នុងពេលដែលពួកគាត់កំពុងជួបបញ្ហាប្រឈមលើការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលតំលៃទីផ្សារ"។

កម្មវិធីជាយុទ្ធសាស្ត្រប្រចាំប្រទេសបច្ចុប្បន្នរបស់ IFAD មានរយៈពេលចាប់ពីឆ្នាំ២០១៣ ដល់ ២០១៨។ កម្មវិធីនេះលើកឡើងអំពីផែនការសហការជាមួយដៃគូរទូទៅ ដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមតំបន់ជនបទ និងគាំទ្រដល់គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ កម្មវិធីនេះមានគោលបំណងបង្កើនលទ្ធភាពរបស់កសិករខ្នាតតូចក្នុងការលក់នៅលើទីផ្សារ បង្កើនសេវាជនបទព្រមទាំងបង្កើនសមត្ថភាពរបស់ពួកគាត់ក្នុងការទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ។

ហិរញ្ញប្បទាន IFAD ដល់ប្រទេសកម្ពុជាសម្រាប់រយៈពេលពីឆ្នាំ២០១៣ដល់២០១៨ មានចំនួនប្រហែល ៥៥លានដុល្លារអាមេរិក។ ក្រៅពីនេះ ទឹកប្រាក់ជំនួយឥតសំណងចំនួន១៥លានដុល្លារត្រូវបាន វិភាជពីកម្មវិធីតំបន់ Adaptation for Smallholder Agriculture Program ដើម្បីប្រើប្រាស់នៅប្រទេសកម្ពុជាក្នុងវិធានការដោះស្រាយ បញ្ហាប្រែប្រួលអាកាសធាតុ។

ចាប់តាំងពីឆ្នាំ១៩៩៦មក IFAD បានវិនិយោគអស់ទឹកប្រាក់ចំនួន១៩០,៩លានដុល្លារនៅក្នុងគម្រោងចំនួន៨ក្នុងប្រទេសកម្ពុជា ដែលទឹកប្រាក់គម្រោងសរុបមានចំនួន ២៨៣,៦លានដុល្លារ។

**ទំនាក់ទំនង**

Jessica Thomas

ផ្នែកទំនាក់ទំនង

ទូរសព្ទ៖ +៣៩ ០៦ ៥៤៥៩ ២២១៥

អ៊ីមែល៖ j.thomas@ifad.org

Susan Beccio

ផ្នែកទំនាក់ទំនង

ទូរសព្ទ៖ +៣៩ ០៦ ៥៤៥៩ ២៤៧៩

អ៊ីមែល៖ s.beccio@ifad.org

*សេចក្តីប្រកាសព័ត៌មានលេខ៖ **IFAD/xx/២០១៥***

*IFAD វិនិយោគទៅលើប្រជាជនជនបទ ដោយផ្តល់អំណាចដល់ពួកគាត់ក្នុងការកាត់បន្ថយភាពក្រីក្រ បង្កើនសន្តិសុខស្បៀង លើកកម្ពស់អាហារូបត្ថម្ភ និងពង្រឹងសមត្ថភាពងើបឡើងវិញ។ ចាប់តាំងពីឆ្នាំ១៩៧៨មក យើងបានផ្តល់ទឹកប្រាក់ប្រហែល ១៦,៦ពាន់លានដុល្លារជាជំនួយឥតសំណង និងកម្ចីការប្រាក់ទាបដល់គម្រោងនានាដែលផ្តល់សេវាដល់ប្រជាជនចំនួនប្រហែល៤៤៥លាននាក់។ IFAD គឺជាគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងជាទីភ្នាក់ងារសហប្រជាជាតិមានមូលដ្ឋាននៅទីក្រុងរ៉ូម ពោលគឺជាមជ្ឈមណ្ឌលស្បៀង និងកសិកម្មរបស់អង្គការសហប្រជាជាតិ។*